**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលជលផល**
**នាយកដ្ឋានអភិរក្សជលផល**

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធានកម្មវិធី REDD+ កម្ពុជា**

**កម្មវត្ថុ** : របាយការណ៍ស្តីពី ការផ្សព្វផ្សាយផ្ទាំងរូបភាពពីអត្ថប្រយោជន៍នៃព្រៃលិចទឹក ដល់អ្នកដែលរស់នៅតំបន់ទំនាបលិចទឹកជាប់កន្លែងអភិរក្ស របស់កម្មវិធី REDD+ កម្ពុជា អតីតឡូត៍នេសាទលេខ១ ខេត្តកំពង់ឆ្នាំង។

**យោង**:
- លិខិតបេសកកម្មលេខ ៥១៧ ជ.ផ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ របស់រដ្ឋបាលជលផល។
- ផែនការកម្មវិធី UN-REDD ថវិកាឆ្នាំ២០១៤ Outcome 2:Development of National Redd+ Strategy and Implementation Framework Activities 2.4 Investigation on how the Redd+ Framework can support management of flooded forests and Mangrove Areas Managed by Fisheries Administration Under Strategic Planning Framework on Fisheries.
- គម្រោងអភិរក្សនិងដាំដុះព្រៃលិចទឹក និងព្រៃកោងកាងឡើងវិញដើម្បីជួយបង្កើនកាបូនស្តុកនិងបន្ថយការបំភាយកាបូន

ន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ក្រុមការងារយើងខ្ញុំសូមរាយការណ៍ជូនឯកឧត្តមមេត្តាជ្រាបដូចខាងក្រោម៖

**១-គោលបំណង**

គោលបំណងនៃបេសកកម្មនេះដើម្បីផ្សព្វផ្សាយផ្ទាំងរូបភាពស្តីពីអត្ថប្រយោជន៍នៃព្រៃលិចទឹកជាមួយអាជ្ញាធរនាយរងខណ្ឌរដ្ឋបាលជលផល និងសហគមន៍ ព្រមទាំងប្រជាពលរដ្ឋឃុំផ្លូវទូក ខេត្តកំពង់ឆ្នាំងដើម្បី៖

- ឲ្យប្រជាពលរដ្ឋបានយល់អំពីសារៈតា និងដំណើរការ នៃការអនុវត្តនៃកម្មវិធី REDD+ កម្ពុជា
- យល់អំពីអត្ថប្រយោជន៍នៃ អភិរក្សព្រៃលិចទឹកចំពោះវិស័យជលផល និងមនុស្ស
- ចេះថែរក្សា ការពារ និង អភិរក្សព្រៃលិចទឹកប្រកបដោយនិរន្តភាព

**២-សមាសភាពចូលរួម**

សមាសភាពចូលរួមចំនួន ៩៦ នាក់ ក្នុងនោះស្រីចំនួន ២០ នាក់ មកពី:

- ក្រុមការងារសម្របសម្រួលរបស់កម្មវិធី REDD+ កម្ពុជា នៃនាយកដ្ឋានអភិរក្សជលផលចំនួន ០២ រូប
- នាយរង ខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង ០១ រូប
- នាយសង្កាត់រដ្ឋបាលជលផលកំពង់លែង ០១ រូប (ប្រធានក្រុមល្បាត)
- មេឃុំផ្លូវទូក ០១ រូប
- មេភូមិពាមខ្នង ឈើទាល និងមេភូមិស្លត ០៣ រូប
- ក្រុមប្រឹក្សាឃុំផ្លូវទូក ០២ រូប (សមាជិកក្រុមល្បាត)
- ប្រជាពលរដ្ឋភូមិស្លត ២៩ រូប
- ប្រជាពលរដ្ឋភូមិឈើទាល ០៥ រូប
- ប្រជាពលរដ្ឋភូមិពាមខ្នង ២៤ រូប
- ប្រជាពលរដ្ឋភូមិប្រលាយមាស ០១ រូប
- សហគមន៍នេសាទផ្លូវទូក ០៦ រូប (សមាជិកក្រុមល្បាត)
- មន្ត្រីបរិស្ថាន ០៣ រូប
- ប្រជាពលរដ្ឋឃុំផ្លូវទូក ២០ រូប

**សរុប** **៩៦ រូប**

### ៣-សកម្មភាពការងារ

ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៤ ក្រុមការងាររបស់នាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផលបានធ្វើការផ្សព្វផ្សាយផ្ទាំងរូបភាពពីអត្ថប្រយោជន៍នៃព្រៃលិចទឹកដល់អាជ្ញាធរឃុំផ្លូវទូកដូចជាៈ ទីប្រឹក្សាឃុំ នគរបាល មន្ត្រីបរិស្ថាន នាយរងខណ្ឌ នាយសង្កាត់កំពង់លែង នៃរដ្ឋបាលជលផល ក្រុមល្បាត សហគមន៍ និង ប្រជាពលរដ្ឋឃុំផ្លូវទូក ខេត្តកំពង់ឆ្នាំង។

ជាកិច្ចចាប់ផ្តើមមន្ត្រីសម្របសម្រួលនៃនាយកដ្ឋានអភិរក្ស បានចែកផ្ទាំងរូបភាពដល់អ្នកចូលរួមពិនិត្យមើលថាតើពួកគាត់យល់ឃើញយ៉ាងណាដែរ? ពួកគាត់បានយកទៅអានហើយយល់ឃើញថា ផ្ទាំងរូបភាពនេះចែកចេញជាពីរ មួយផ្នែកអាក្រក់ និងមួយផ្នែកទៀតល្អ។ ប៉ុន្តែពួកគាត់ពុំបានយល់ឲ្យបានស៊ីជម្រៅជាងនេះទេ។

ជាបន្តក្រុមអ្នកសម្របសម្រួលបានពន្យល់ដល់ប្រជាពលរដ្ឋ អំពីអត្ថន័យនៃផ្ទាំងរូបភាពព្រៃលិចទឹកសាប និងប្រៃថាៈ ព្រៃលិចទឹកសាបគឺជាព្រៃដែលរស់នៅតំបន់ទំនាបលិចទឹក ពិសេសតំបន់ទន្លេសាប ឯព្រៃលិចទឹកប្រៃឬភ្លៀវគឺជាព្រៃកោងកាង។ ក្នុងនោះកម្មវិធីរេដបូកបានជ្រើសរើសយកខេត្តចំនួនពីរគឺៈ ព្រៃទឹកសាបមានទីតាំងនៅក្នុងឃុំផ្លូវទូក (អតីតឡូតិ៍លេខ១) ស្រុក កំពង់លែង ខេត្តកំពង់ឆ្នាំង និងព្រៃកោងកាងស្ថិតក្នុងខេត្តព្រះសីហនុ។ ប្រភេទទីតាំងព្រៃទាំងពីរនេះត្រូវបានអភិរក្សក្រោមការឧបត្ថម្ភរបស់កម្មវិធីREDD+កម្ពុជា។

ផ្នែកខាងឆ្វេងនៃរូបភាពបានបង្ហាញថា ពេលកាប់ឬដុតព្រៃឈើ ផ្សែងរោងចក្រ ផ្សែងកាណូតបានបំភាយចេញនូវឧស្ម័នកាបូនិក បង្កឲ្យមានខ្យល់ពុល នឹងបង្កើតជាឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងធ្វើឲ្យបរិយាកាសប្រែប្រួល បាត់បង់អុកស៊ីសែន ជាពិសេសធ្វើឲ្យបាត់បង់នូវ ប្រភពចំណី ជម្រក កន្លែងពងកូនរបស់មច្ឆជាតិ ដោយសារការ បាត់បង់ព្រៃឈើ។ ដូចនេះព្រៃឈើវាផ្តល់ផលប្រយោជន៍ដល់អស់លោកអ្នកតាំងពីកើតដល់ស្លាប់។

### ៤-ផលវិបាក

១- ប្រជាពលរដ្ឋ ៥០% ពុំចេះអក្សរដែលពិបាកធ្វើការពន្យល់ដល់ពួកគាត់

២- ចម្ងាយពីភូមិមួយទៅភូមិមួយទៀតដាច់ឆ្ងាយពីគ្នា ពិបាកនិងអញ្ជើញពួកគាត់មកចូលរួម

៣- ភាគច្រើនបុរសជាមេគ្រួសារមានការរវល់ជាប់ការងារនេសាទ ឬធ្វើស្រែចំការ ច្រើនតែឲ្យប្រពន្ធឬនារីមកចូលរួម

### ៥-ដំណោះស្រាយ

សហគមន៍នេសាទ អាជ្ញាធរឃុំ នាយរងខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង និងនាយសង្កាត់រដ្ឋបាលជលផលកំពង់លែងបានសំណូមពរថាគួរមានការផ្សព្វផ្សាយ ដោយមិនកំនត់បរិមាណដល់ប្រជាពលរដ្ឋចូលរួមទូទៅក្នុងពេលជិតប្រារព្ធពិធីបុណ្យទាននៅក្នុងតំបន់ដើម្បីឲ្យពួកគាត់បានយល់និងស្គាល់តំបន់អភិរក្សទើបគាត់ចូលរួមការពារ និងឈប់កាប់រានព្រៃធ្វើចំការបន្តទៀត។

### ៦-លទ្ធផលការងារ

ការផ្សព្វផ្សាយនេះប្រជាពលរដ្ឋបានយល់ដឹងកាន់តែច្បាស់ថែមទៀត នូវផលប្រយោជន៍ព្រៃលិចទឹក មិនគ្រាន់តែប្រភពចំណី ជម្រក កន្លែងពងកូនរបស់មច្ឆជាតិប៉ុណ្ណោះទេ វាជួយបន្សុទ្ធខ្យល់បរិយាកាស ទប់ទល់នូវបំរែបំរួលបរិយាកាស ។ កិច្ចផ្សព្វផ្សាយនេះប្រជាពលរដ្ឋបានចូលរួមគ្រប់ផែនការដែលបានគ្រោងទុកប្រកបដោយភាពស្និទ្ធស្នាល ជាទីបំផុត។

### ៧-ទិសដៅបន្ត

ក្រុមការងារនាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផលនឹងចុះទៅធ្វើការផ្សព្វផ្សាយបន្ថែម ទៀតស្តីពីតំបន់ការពារព្រៃលិចទឹកដល់សហគមន៍មូលដ្ឋាន ដើម្បីឲ្យគាត់ស្គាល់តំបន់អភិរក្ស និងចូលរួមជួយការពារព្រៃលិច ទឹកឈប់កាប់រានបន្តទៀត។

### ៨-អនុសាសន៍

ការផ្សព្វផ្សាយ មិនត្រូវមានការកំនត់ គួរណាស់តែគូជាផ្ទាំងរូបភាព បោះដាក់តាំង ផ្សាយនៅទីប្រជុំជនតំបន់ព្រៃលិចទឹក ឬផលិតជាខ្សែវីដេអូ ងាយៗ ដោយបង្កប់នៃការពារ ថែរក្សា និងអភិរក្សផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានកម្មវិធីផង មេត្តាជ្រាបជារបាយការណ៍ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៤

អ្នកធ្វើរបាយការណ៍

លី សុធា

បានឃើញ និងឯកភាព

ត. ប្រធាននាយកដ្ឋានអភិរក្សជលផល

ប៊ុន សុី

Date: 10/03/2014

# រូបភាពសកម្មភាព
# ផ្សព្វផ្សាយផ្ទាំងរូបភាពព្រៃលិចទឹក នៃកម្មវិធីរេដបូក



រូបភាពទី១ សកម្មភាព
ចុះបញ្ជីអវត្តមាននៃអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋចូលរួម



រូបភាពទី២ សកម្មភាពសំណេះសំណាល និងណែនាំខ្លួន
មុនធ្វើការផ្សព្វផ្សាយផ្ទាំងរូបភាពនៃអត្ថប្រយោជន៍ព្រៃលិចទឹក



រូបភាពទី៣ សកម្មភាពបង្ហាញ
និងពន្យល់ផ្ទាំងរូបភាព អំពីអត្ថប្រយោជន៍នៃព្រៃលិចទឹក



រូបភាពទី៤ សកម្មភាពសួរបញ្ជាក់ឡើងវិញ
ដល់អ្នកចូលរួមដើម្បីវាស់វែងការយល់ដឹងរបស់គាត់កំរិតណា
ក្រោយពីក្រុមអ្នកសម្របសម្រួលបានបង្ហាញនិងពន្យល់ដល់ពួកគាត់